**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:**...២១០...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩៣១/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងរៀបចំការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធឱ្យមាននិរន្តរភាពនិងប្រសិទ្ធភាព ស្របតាមគោលនយោបាយអប់រំក្រៅប្រព័ន្ធរបស់រាជរដ្ឋាភិបាល។

**មាត្រា២ ..**

អនុក្រឹត្យនេះ មានគោលដៅដើម្បីកំណត់នូវៈ

- ការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ
- ការប្រើប្រាស់ បែបបទ និងនីតិវិធីនៃការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធដើម្បីបំពេញបន្ថែមលើការអប់រំក្នុងប្រព័ន្ធ
- ប្រាក់កម្រៃ និង ការបើកផ្តល់ប្រាក់កម្រៃជូនគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ
- ការគ្រប់គ្រង ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការងារបង្រៀនតាមគ្រប់កម្មវិធីអប់រំក្រៅប្រព័ន្ធ។

**មាត្រា៣ ..**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និង ការគ្រប់គ្រងសេវាបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤ ..**

ពាក្យសម្រាប់ប្រើប្រាស់ក្នុងអនុក្រឹត្យនេះមាននិយមន័យកំណត់ដូចខាងក្រោមៈ

- គណៈគ្រប់គ្រងកម្មវិធីបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ សំដៅដល់គណៈកម្មការនីមួយៗក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ ដែលត្រូវសម្រេចទទួលស្គាល់ដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ សំដៅដល់អ្នកធ្វើការងារដឹកនាំនិងគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍រយៈពេល១២ខែ
- កម្មវិធីអប់រំក្រៅប្រព័ន្ធ សំដៅដល់កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូលបឋមសិក្សា និងកម្មវិធីបង្កើនប្រាក់ចំណូល
- កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ សំដៅដល់កម្មវិធីថ្មីមួយដែលធ្វើឱ្យអ្នករៀនចេះអាន សរសេរ គិតលេខ អាចដោះស្រាយបញ្ហាពាក់ព័ន្ធនឹងជីវភាពរស់នៅផ្ទាល់របស់គេ
- កម្មវិធីចូលរៀនឡើងវិញ សំដៅដល់កម្មវិធីជួយដល់សិស្សដែលបានបោះបង់ការសិក្សាតាមថ្នាក់នីមួយៗនៃបឋមសិក្សាចំណេះទូទៅ ឱ្យគេបានវិលចូលរៀនតាមកម្រិតថ្នាក់នៃសាលារៀនចំណេះទូទៅវិញ
- កម្មវិធីសមមូលបឋមសិក្សា សំដៅដល់កម្មវិធីដែលជ្រើសសម្រាំងទាំងខ្លឹមសារ ទាំងមុខវិជ្ជាសំខាន់ៗពីកម្មវិធីសិក្សាក្នុងប្រព័ន្ធ (សាលារៀនចំណេះទូទៅ) ដោយផ្សារភ្ជាប់នឹងកម្មវិធីបណ្តុះបណ្តាលមុខរបរ
- កម្មវិធីបង្កើនប្រាក់ចំណូល សំដៅដល់កម្មវិធីជួយអ្នករៀនឱ្យចេះរកប្រាក់ចំណូលដើម្បីកែលម្អជីវភាពរស់នៅរបស់គេ
- គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ សំដៅដល់គ្រូបង្រៀនតាមកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូលបឋមសិក្សា និងកម្មវិធីបង្កើនប្រាក់ចំណូល

## ជំពូកទី២
## ការប្រើប្រាស់ បែបបទ និងនីតិវិធីនៃការជ្រើសរើស
## គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ

**មាត្រា៥ ..**

ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ត្រូវអនុវត្តក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធរួមមាន៖ កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូលបឋមសិក្សា និងកម្មវិធីបង្កើនប្រាក់ចំណូល ដែលរៀបចំនៅតាមមូលដ្ឋានដែលមានអត្រាសិស្សបោះបង់ការសិក្សានិងអត្រាអនក្ខរជនខ្ពស់។

ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ត្រូវបានផ្តល់ជាអាទិភាពសម្រាប់បំពេញការងារបង្រៀនជំនួសការបង្រៀនតាមកម្មវិធីអប់រំក្នុងប្រព័ន្ធ ដើម្បីផ្តល់ឱកាសជាថ្មីដល់កុមារ យុវជននៅក្រៅសាលា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កម្មករ និយោជិត និងមនុស្សពេញវ័យទាំងអស់ ដែលមិនមានឱកាសរៀននៅតាមសាលារៀនអប់រំក្នុងប្រព័ន្ធ អាចចូលរៀនឬបន្តការសិក្សាឡើងវិញតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ។

**មាត្រា៦ ..**

ការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ត្រូវអនុវត្តដោយគណៈកម្មការដែលដឹកនាំដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និង មានការចូលរួមពីតំណាងមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត។

គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ត្រូវប្រកាសទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត បន្ទាប់ពីទទួលបានទិដ្ឋាការពីមន្ទីរមុខងារសាធារណៈរាជធានី ខេត្តពាក់ព័ន្ធ។

បែបបទ និង នីតិវិធីនៃការជ្រើសរើសនិងការគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៧ ..**

ការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធត្រូវជ្រើសរើសចេញពី៖

- បេក្ខជនដែលមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬសញ្ញាបត្រសមមូលឡើងទៅ ឬបេក្ខជនដែលមានជំនាញបច្ចេកទេសស្របតាមសេចក្តីត្រូវការនៃការបណ្តុះបណ្តាល
- គ្រូបង្រៀនគ្រប់ប្រភេទក្របខណ្ឌ ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍។

ការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធត្រូវបានផ្តល់អាទិភាពដល់៖

- បេក្ខជនដែលកំពុងរស់នៅក្នុងមូលដ្ឋានដែលមានថ្នាក់កម្មវិធីអប់រំក្រៅប្រព័ន្ធ
- បេក្ខជនជាជនពិការនិងស្ត្រី។

គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធដែលត្រូវបានជ្រើសរើសថ្មី ត្រូវមានការបំប៉នរយៈពេលខ្លីដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡាលើផ្នែកជំនាញបច្ចេកទេស វិធីសាស្ត្របង្រៀន ចិត្តគរុកោសល្យនិងការងាររដ្ឋបាល។

**មាត្រា៨ ..**

គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ត្រូវបំពេញភារកិច្ចបង្រៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ តាមការរៀបចំរបស់ក្រសួងអប់រំ យុវជន និងកីឡានិងទទួលប្រាក់កម្រៃដូចមានកំណត់ក្នុងមាត្រា១១នៃអនុក្រឹត្យនេះ ប៉ុន្តែពុំមានបុព្វសិទ្ធិដូចមន្ត្រីរាជការជាគ្រូបង្រៀនទេ។

**មាត្រា៩ ..**

គណៈគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធដោយពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានមុខសញ្ញាអប់រំក្រៅប្រព័ន្ធក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយដាក់សំណើផែនការនេះមកក្រសួងអប់រំ យុវជន និងកីឡា តាមរយៈការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវពិគ្រោះយោបល់ជាមួយមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត មុននឹងដាក់សំណើផែនការនេះទៅក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំសេចក្តីណែនាំអំពីបែបបទនិងនីតិវិធីនៃការរៀបចំផែនការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធនៅតាមរាជធានី ខេត្ត ផ្អែកលើផែនការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធប្រចាំឆ្នាំដែលត្រូវពិនិត្យនិងអនុម័តក្នុងថវិកាប្រចាំឆ្នាំនីមួយៗរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## និយាមនៃកម្មវិធីអប់រំក្រៅប្រព័ន្ធនិងប្រាក់កម្រៃ
## សម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ

**មាត្រា១០ ..**

កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ បង្រៀនយ៉ាងតិចចំនួន១០(ដប់)ម៉ោងក្នុង១(មួយ)សប្តាហ៍ ឬចំនួន៤០(សែសិប)ម៉ោងក្នុង១(មួយ)ខែ និង ត្រូវបង្រៀនរយៈពេល៧(ប្រាំពីរ)ខែ ហើយ១(មួយ)ខែសម្រាប់រៀបចំឯកសារបង្រៀននិងប្រមូលសិស្សចូលរៀន។ គ្រូបង្រៀនកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ ទទួលបានប្រាក់កម្រៃសរុបរយៈពេល៨(ប្រាំបី)ខែ និង ត្រូវបង្រៀនសរុបចំនួន២៩០(ពីររយកៅសិប)ម៉ោង។

កម្មវិធីចូលរៀនឡើងវិញ បង្រៀនយ៉ាងតិចចំនួន២៤(ម្ភៃបួន)ម៉ោងក្នុង១(មួយ)សប្តាហ៍ ឬ ចំនួន៩៦(កៅសិបប្រាំមួយ)ម៉ោងក្នុង១(មួយ)ខែ និង ត្រូវបង្រៀនរយៈពេល២(ពីរ)ខែ។ គ្រូបង្រៀនកម្មវិធីចូលរៀនឡើងវិញ ទទួលបានប្រាក់កម្រៃសរុបរយៈពេល២(ពីរ)ខែ និងត្រូវបង្រៀនសរុបចំនួន១៩២(មួយរយកៅសិបពីរ)ម៉ោង។

កម្មវិធីសមមូលបឋមសិក្សា បង្រៀនយ៉ាងតិចចំនួន១០(ដប់)ម៉ោងក្នុង១(មួយ)សប្តាហ៍ ឬ ចំនួន៤០(សែសិប)ម៉ោងក្នុង១(មួយ)ខែនិងត្រូវបង្រៀនរយៈពេល១០(ដប់)ខែ។ គ្រូបង្រៀនកម្មវិធីសមមូលបឋមសិក្សា ទទួលបានប្រាក់កម្រៃសរុបរយៈពេល១០(ដប់)ខែ និងត្រូវបង្រៀនសរុបចំនួន ៤០០(បួនរយ)ម៉ោង។

កម្មវិធីបង្កើនប្រាក់ចំណូល បង្រៀនចំនួនពី២៤(ម្ភៃបួន) ទៅ ៣០(សាមសិប)ម៉ោងក្នុង១(មួយ)សប្តាហ៍ឬចំនួនពី៩៦(កៅសិបប្រាំមួយ) ទៅ ១២០(មួយរយម្ភៃ)ម៉ោងក្នុង១(មួយ)ខែ និង ត្រូវបង្រៀនរយៈពេលពី១(មួយ)ខែ ទៅ ៦(ប្រាំមួយ)ខែ អាស្រ័យទៅតាមមុខជំនាញនីមួយៗ។ គ្រូបង្រៀនកម្មវិធីបង្កើនប្រាក់ចំណូល ទទួលបានប្រាក់កម្រៃសរុបអាស្រ័យទៅតាមរយៈពេលនៃមុខជំនាញនីមួយៗ។

**មាត្រា១១ ..**

គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ដែលត្រូវបានជ្រើសរើសសម្រាប់ការបង្រៀនក្នុងកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូលបឋមសិក្សា និងកម្មវិធីបង្កើនប្រាក់ចំណូល ផ្អែកតាមបទបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវបានផ្ដល់ប្រាក់កម្រៃប្រចាំខែចាប់ពីពេលដែលបានចាប់ផ្ដើមរហូតដល់ពេលដែលសាមីខ្លួនបានបញ្ចប់ភារកិច្ចដូចខាងក្រោម៖

- ស្មើនឹង៥០% (ហាសិបភាគរយ) នៃបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋមដែលទើបត្រូវបានជ្រើសរើសថ្មី ចំពោះគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធសម្រាប់កម្មវិធីអក្ខរកម្មវិជ្ជាជីវៈនិងកម្មវិធីសមមូលបឋមសិក្សា ដែលបានជ្រើសរើសពីបេក្ខជនដែលមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬសញ្ញាបត្រសមមូលឡើងទៅ
- ស្មើនឹង៦០%(ហុកសិបភាគរយ) នៃបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋមដែលទើបត្រូវបានជ្រើសរើសថ្មី ចំពោះគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធសម្រាប់កម្មវិធីអក្ខរកម្មវិជ្ជាជីវៈនិងកម្មវិធីសមមូលបឋមសិក្សា ដែលបានជ្រើសរើសពីគ្រូបង្រៀនចូលនិវត្តន៍គ្រប់ប្រភេទក្របខណ្ឌ
- ស្មើនឹង៨០%(ប៉ែតសិបភាគរយ) នៃបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋមដែលទើបត្រូវបានជ្រើសរើសថ្មី ចំពោះគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធសម្រាប់កម្មវិធីចូលរៀនឡើងវិញ ដែលបានជ្រើសរើសពីបេក្ខជន ដែលមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិឬសញ្ញាបត្រសមមូលឡើង
- ស្មើនឹង៩០%(កៅសិបភាគរយ) នៃបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋម ដែលទើបត្រូវបានជ្រើសរើសថ្មី ចំពោះគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធសម្រាប់កម្មវិធីចូលរៀនឡើងវិញ ដែលបានជ្រើសរើសពីគ្រូបង្រៀនចូលនិវត្តន៍គ្រប់ប្រភេទក្របខណ្ឌ
- ស្មើនឹង១០០%(មួយរយភាគរយ) នៃបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋមដែលទើបត្រូវបានជ្រើសរើសថ្មី ចំពោះគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធសម្រាប់កម្មវិធីបង្កើនប្រាក់ចំណូល ដែលបានជ្រើសរើសពីអ្នកជំនាញបច្ចេកទេសក្នុងនិងក្រៅសហគមន៍។

**មាត្រា១២ ..**

ប្រាក់កម្រៃប្រចាំខែដែលត្រូវបើកផ្ដល់ឱ្យគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ត្រូវអនុវត្តតាមតារាងទូទាត់បៀវត្សគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈ។

## ជំពូកទី៤
## ការគ្រប់គ្រង ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការបង្រៀន
## តាមកម្មវិធីអប់រំក្រៅប្រព័ន្ធ

**មាត្រា១៣ ..**

គណៈគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធ ត្រូវសម្រេចទទួលស្គាល់ដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីដឹកនាំនិងគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធនីមួយៗ។

គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ មានសមាសភាពយ៉ាងច្រើនបំផុតចំនួន ៥ (ប្រាំ) រូប ដើម្បីបំពេញការងារដឹកនាំនិងគ្រប់គ្រងមជ្ឈមណ្ឌល និង ទទួលបានការផ្តល់ប្រាក់លើកទឹកចិត្តចំនួន ១០០ ០០០៛ (មួយសែនរៀល) សម្រាប់ម្នាក់ៗក្នុង១(មួយ)ខែ។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចទទួលស្គាល់សមាសភាពនេះនិងទទួលខុសត្រូវបើកផ្តល់ប្រាក់លើកទឹកចិត្តប្រចាំខែ។

ការចាត់តាំងសមាសភាពនៅក្នុងគណៈគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធនិងគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ត្រូវអនុវត្តអនុលោមតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ការបង្កើតនិងការបិទមជ្ឈមណ្ឌលសិក្សាសហគមន៍ ត្រូវសម្រេចដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការបង្កើតមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលទ្រទ្រង់ដោយថវិកាជាតិ ត្រូវមានការពិគ្រោះយោបល់ជាមុនជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៤ ..**

គណៈគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធដូចជា កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូលបឋមសិក្សា និងកម្មវិធីបង្កើនប្រាក់ចំណូលជាដើម ដែលរៀបចំនៅតាមមូលដ្ឋានឃុំ សង្កាត់ គ្រឹះស្ថានសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬទីតាំងដទៃទៀត ត្រូវពិនិត្យ គ្រប់គ្រង និងចាត់ចែងសេវាបង្រៀនឱ្យមានប្រសិទ្ធភាពអនុលោមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ការស្នើជ្រើសរើសនិងចាត់តាំងគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ត្រូវពិនិត្យនិងរៀបចំដោយគណៈគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធក្រុង ស្រុក ខណ្ឌ ដោយមានការដឹកនាំពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។

គណៈគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធ ត្រូវលើកសំណើអំពីការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធមកមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីពិនិត្យនិងសម្រេចតាមរយៈការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ផ្អែកលើផែនការប្រចាំឆ្នាំដែលទទួលបានការអនុម័តក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរួចហើយ។

**មាត្រា១៥ ..**

គណៈគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធ ត្រូវគ្រប់គ្រងនិងចាត់ចែងការងារ ព្រមទាំងត្រូវមានគណនេយ្យភាពនិងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការធានានូវប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធនិងការបើកផ្តល់ប្រាក់កម្រៃជូនគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធក្រោមការគ្រប់គ្រងរបស់ខ្លួន។

ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និង ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានគណនេយ្យភាពនិងការទទួលខុសត្រូវចំពោះការត្រួតពិនិត្យនិងណែនាំការបំពេញការងាររបស់គណៈគ្រប់គ្រងក្នុងការអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូលបឋមសិក្សា និងកម្មវិធីបង្កើនប្រាក់ចំណូលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៦ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើការត្រួតពិនិត្យនិងវាយតម្លៃអំពីស្ថានភាពនៃការគ្រប់គ្រងនិងការចាត់ចែងការបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធនៅរៀងរាល់ដំណាច់ឆ្នាំសិក្សានីមួយៗ ដោយផ្អែកលើភាពចាំបាច់នៃការងារក្នុងគោលដៅបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការប្រើប្រាស់ធនធានមនុស្សគាំទ្រដល់សេវាបង្រៀន។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៧ ..**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ |
|---|---|---|
| **អូន ព័ន្ធមុនីរ័ត្ន** | **ហង់ ជួន ណារ៉ុន** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ